

# ដល់ពេលដែលត្រូវវាយតម្លៃលើ ការវិនិយោគក្នុងវិស័យថាមពល

## នៅមហាអនុតំបន់ទន្លេមេគង្គ

INTERNATIONAL RIVERS
people • water • life

Mekong Watch

ខែកញ្ញា ឆ្នាំ២០១៥

## ដល់ពេលដែលត្រូវវាយតម្លៃលើការវិនិយោគក្នុងវិស័យថាមពលនៅមហាអនុតំបន់ទន្លេមេគង្គ

និពន្ធដោយៈ តានយ៉ា លី (Tanya Lee)

បោះពុម្ពផ្សាយដោយៈ អង្គការទន្លេអន្តរជាតិ និងអង្គការឃ្លាំមើលទន្លេមេគង្គ

ខែកញ្ញា ឆ្នាំ២០១៥

ការទទួលស្គាល់ៈ ការវិភាគនៅទីនេះគឺជាការឆ្លុះបញ្ចាំងរបស់អង្គការទន្លេអន្តរជាតិ និងអង្គការឃ្លាំមើលទន្លេមេគង្គ វាមិនមែនជាការឆ្លុះបញ្ចាំងរបស់អ្នកផ្តល់មូលនិធិ ឬក្រុមអ្នកពិនិត្យម្នាក់ៗនោះទេ។

រូបថតគម្របមុខៈ ក្រុមគ្រួសារដែលរស់នៅតាមដងទន្លេ Xekaman, ឃើញមានដីស្រែចំការនិងផ្ទះសម្បែងរបស់ពួកគាត់ត្រូវជន់លិចដោយទំនប់វារីអគ្គិសនីជាច្រើនដែលពាក់ព័ន្ធនឹងអន្តរបណ្តាញថាមពលអគ្គិសនីរវាងសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ និងសាធារណរដ្ឋសង្គមនិយមវៀតណាម។ ស្ត្រីស្ថិតក្នុងចំណោមអ្នករងគ្រោះខ្លាំងជាងគេបំផុត នៅពេលប្រឈមមុខនឹងអសន្តិសុខនៃការដកហូតដីធ្លីដែលអាចនឹងកើតឡើងជាក់ស្តែង ព្រោះថា ពួកគាត់ជាធម្មតា ជាអ្នកមើលថែទាំកូនៗ មនុស្សចាស់ជរា និងអ្នកជំងឺ។

រូបថតគម្របខាងក្រោយៈ ទន្លេសេកុង ក្នុងស្រុកកាឡឹម (Kaleum) សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ

រូបថតទាំងអស់បានមកពីៈ អង្គការទន្លេអន្តរជាតិ

គាំទ្រដោយៈ OXFAM

# ដល់ពេលដែលត្រូវវាយតម្លៃលើការវិនិយោគក្នុងវិស័យថាមពលនៅមហាអនុតំបន់ទន្លេមេគង្គ

### តើធនាគារអភិវឌ្ឍន៍អាស៊ី និងធនាគារពិភពលោកមានតួនាទីអ្វីខ្លះក្នុងវិស័យថាមពលអគ្គិសនីនៅក្នុងតំបន់ទន្លេមេគង្គ?

តាមរយៈកម្មវិធីមហាអនុតំបន់ទន្លេមេគង្គ (GMS) ធនាគារពិភពលោក និងធនាគារអភិវឌ្ឍន៍អាស៊ី (ADB) កំពុងផ្តល់ហិរញ្ញប្បទានដល់គម្រោងហេដ្ឋារចនាសម្ព័ន្ធថាមពល នៅក្នុងតំបន់ និងការសិក្សាបច្ចេកទេសនៅក្នុងវិស័យថាមពលក្នុងតំបន់។ ការវិនិយោគត្រូវបានចង្អុលបង្ហាញដោយផែនការថាមពលមហាអនុតំបន់ទន្លេមេគង្គ ដោយផ្តល់អាទិភាពលើការអភិវឌ្ឍបណ្តាញអគ្គិសនីនៅក្នុងតំបន់ដែលត្រូវបានស្នើឡើងក្នុងការផ្គត់ផ្គង់ថាមពលយ៉ាងលើសលប់ តាមរយៈទំនប់វារីអគ្គិសនីនៅតាមដៃទន្លេ និងទន្លេធំនៃអាងទន្លេមេគង្គក្រោម។ ជាលទ្ធផលការផ្តល់មូលនិធិដោយធនាគារអភិវឌ្ឍន៍អាស៊ី និងធនាគារពិភពលោក ជួយដោយផ្ទាល់ក្នុងការអភិវឌ្ឍបង្គោលខ្សែភ្លើងវ៉ុលខ្ពស់ដែលជាតម្រូវការសម្រាប់ប្រព័ន្ធអន្តរបណ្តាញនេះ និងដើម្បីជួលក្រុមហ៊ុនពិគ្រោះយោបល់ឲ្យវិភាគលើជម្រើសនៃការអភិវឌ្ឍវិស័យថាមពល។

### តើមានបញ្ហាអ្វីខ្លះ?

- ភាពខុសគ្នាគួរឱ្យកត់សម្គាល់កើតមានរវាងការវិនិយោគថាមពលនៅក្នុងមហាអនុតំបន់ទន្លេមេគង្គ និងអនុសាសន៍ពីការស្រាវជ្រាវមួយដែលធ្វើឡើងដោយស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ រួមទាំងធនាគារអភិវឌ្ឍន៍អាស៊ីផង។
  - ខណៈពេលដែលក្រុមហ៊ុនពិគ្រោះយោបល់ដែលជួលដោយធនាគារអភិវឌ្ឍន៍អាស៊ី ផ្តល់អនុសាសន៍ឲ្យបង្កើនហិរញ្ញប្បទានលើកម្មវិធីប្រសិទ្ធផលថាមពល និងថាមពលកកើតឡើងវិញ (មិនរួមបញ្ចូលវារីអគ្គិសនីធំៗ) សម្រាប់មហាអនុតំបន់ទន្លេមេគង្គ ការវិនិយោគលើវិស័យនេះបែរជាមាននិន្នាការផ្តោតលើការជំរុញឲ្យមានទំនប់វារីអគ្គិសនីធំៗ និងហេដ្ឋារចនាពាក់ព័ន្ធទៅវិញ។
- ការវិនិយោគថាមពលក្នុងមហាអនុតំបន់ទន្លេមេគង្គខ្វះតម្លាភាពនិងគណនេយ្យភាព។
  - អវត្តមានការពិគ្រោះយោបល់ជាផ្លែផ្កានិងដំណើរការនៃការធ្វើសេចក្តីសម្រេចដែលមានអង្គការមិនមែនរដ្ឋាភិបាល (NGOs) អង្គការសង្គមស៊ីវិល (CSOs) និងសហគមន៍ដែលរងផលប៉ះពាល់ចូលរួមនៅថ្នាក់មូលដ្ឋាន ថ្នាក់ជាតិ និងថ្នាក់តំបន់។ បើគ្មានដំណើរការដែលមានការចូលរួមសម្រាប់ការធ្វើផែនការវិស័យថាមពល នៅថ្នាក់តំបន់ ថ្នាក់ជាតិ ឬថ្នាក់មូលដ្ឋានទេ អ្នកធ្វើការសម្រេចចិត្តអាចនៅតែគ្មានការទទួលខុសត្រូវដដែល។
- ការចំណាយលើផ្នែកបរិស្ថាននិងសង្គមពាក់ព័ន្ធការវិនិយោគលើវិស័យថាមពលរបស់មហាអនុតំបន់ទន្លេមេគង្គ មិនត្រូវបានវាយតម្លៃបន្ថែម ដោយផ្អែកលើមូលដ្ឋានឆ្លងដែនទេ ឬមិនត្រូវបានបញ្ចូលទៅក្នុងគម្រោងចំណាយ-ចំណេញ និងទំនាក់ទំនងជាំនាប៉ប់រងទេ។ លើសពីនេះទៅទៀត ការចំណាយលើការឈប់ជួលអ្នកពិគ្រោះយោបល់ដែលពាក់ព័ន្ធនៅតែបង្ហាញជាគំនិតនៅឡើយ។

### តើគណៈគ្រប់គ្រងរបស់ធនាគារអភិវឌ្ឍន៍អាស៊ី និងធនាគារពិភពលោកអាចធ្វើអ្វីខ្លះ?

- ធ្វើបច្ចុប្បន្នភាពនូវគោលនយោបាយស្តីពីថាមពលរបស់ស្ថាប័នរៀងៗខ្លួនដើម្បីដកចេញនូវគម្រោងវារីអគ្គិសនីខ្នាតធំដែលជាជម្រើសថាមពលកកើតឡើងវិញ,
- បញ្ចូលនូវជម្រើសថាមពលទាំងអស់ដែលអាចប្រើបានទៅក្នុងការសម្រេចចិត្តផ្នែកថាមពលមុនពេលអនុម័តគម្រោង រួមទាំងការពិចារណាលើអនុសាសន៍ដែលបានផ្តល់ជូននៅក្នុងរបាយការណ៍សិក្សាអំពីវិស័យថាមពលរបស់មហាអនុតំបន់ទន្លេមេគង្គ ដែលធនាគារអភិវឌ្ឍន៍អាស៊ីបានចាត់ចែងឲ្យធ្វើ,
- អនុវត្តដំណើរការពិគ្រោះយោបល់ជាមួយសហគមន៍ប្រកបដោយផ្លែផ្កា រួមទាំងការងារពាក់ព័ន្ធនឹងការវាយតម្លៃអំពីជម្រើសប្រភពថាមពល និងតម្រូវការ,
- ស្វែងរកគំនិតល្អៗពីក្រុមសង្គមស៊ីវិល បណ្តាញនានា និងអង្គការដែលមានមូលដ្ឋាននៅតាមសហគមន៍,
- តម្រូវឱ្យមានការវាយតម្លៃល្អិតល្អន់អំពីផលប៉ះពាល់ផ្នែកសិទ្ធិមនុស្ស និងផ្នែកសមភាពយេនឌ័រក្នុងការចូលរួមដោយលទ្ធផលនៃសកម្មភាពត្រូវបានអនុវត្តសម្រាប់គ្រប់គម្រោងវិស័យថាមពល,
- ទទួលស្គាល់របាយការណ៍តាមដានការរំលោភគោលការណ៍ការពារសុវត្ថិភាពពាក់ព័ន្ធនឹងគម្រោងវារីអគ្គិសនីធំៗ ព្រមទាំងដកខ្លួនចេញពីការផ្តល់ហិរញ្ញប្បទានទំនប់វារីអគ្គិសនីធំៗ និងស្ថានីយដែលពាក់ព័ន្ធ, និង
- អនុម័តលើបណ្តាគម្រោង ដោយមានដំណើរការកាន់តែមានតម្លាភាពបន្ថែមទៀត ដែលជាការទទួលខុសត្រូវចំពោះ និងបំពេញតាមតម្រូវការរបស់ប្រជាជននៅក្នុងតំបន់។

# ករណីសិក្សាអំពីគម្រោងថាមពលនៅសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិត ឡាវ ដែលផ្សព្វផ្សាយដោយកម្មវិធីមហាអនុតំបន់ទន្លេមេគង្គ

## លេខគម្រោង 41450–012៖ អន្តរបណ្តាញថាមពលអគ្គិសនីឡាវ – វៀតណាម (HATXAN – PLEIKU)

**ស្ថានភាព៖ មិនបានអនុម័ត**

**ការសាងសង់កំពុងដំណើរការ (ដោយក្រុមហ៊ុនវៀតណាម)**

អន្តរបណ្តាញថាមពលអគ្គិសនី ឡាវ – វៀតណាមមានពាក់ព័ន្ធនឹងការសាងសង់បង្គោលភ្លើងប្រវែងជាង១៥០គីឡូម៉ែត្រ និងស្ថានីយរងមួយនៅ Hatxan ប្រទេសឡាវ ដើម្បីបញ្ជូនថាមពលពីទំនប់វារីអគ្គិសនីពាក់ព័ន្ធចំនួនប្រាំបីនៅភាគខាងត្បូងប្រទេសឡាវ ទៅប្រទេសវៀតណាម។ គម្រោងវារីអគ្គិសនីពាក់ព័ន្ធទាំងអស់សម្រាប់គម្រោង តភ្ជាប់នេះ ត្រូវបានគ្រោងបញ្ចូលទៅក្នុងអាងទន្លេសេកុងដែលជាទន្លេឆ្លងដែន នៅក្នុងប្រទេសឡាវ រួមមានគម្រោងវារីអគ្គិសនី Xekaman 1, Xekaman 4 និងសេកុង 3 (ខ្សែទឹកខាងលើនិងខាងក្រោម)។ ការសាងសង់ទំនប់ទន្លេសេកុងនិងទន្លេ Sekaman នៅតាមតំបន់ជាច្រើន នឹងបង្កប៉ះពាល់មិនត្រឹមតែចំពោះជីវភាពរស់នៅរបស់ប្រជាជនរាប់សិបពាន់នាក់ដែលរស់នៅតាមដងទន្លេនៅក្នុងប្រទេសឡាវ និងកម្ពុជាតែប៉ុណ្ណោះនោះទេ ប៉ុន្តែវាថែមទាំងបង្កឱ្យមានការបាត់បង់យ៉ាងខ្លាំង (តាមការប៉ាន់ប្រមាណថាបាត់បង់៩%) នូវជីវម៉ាស់ត្រី និងជីវចម្រុះនៅទូទាំងអាងទន្លេមេគង្គទាំងមូល ដោយសារតែមានពូជត្រីយ៉ាងច្រើនដែលរស់នៅតំបន់នោះផ្លាស់ទីចេញ។[1]

ចាប់តាំងពីការចាប់ផ្តើមគម្រោងនេះ អង្គការទន្លេអន្តរជាតិបានអំពាវនាវឱ្យធនាគារអភិវឌ្ឍន៍អាស៊ី កំណត់ទំនប់វារីអគ្គិសនីនេះជាស្ថានីយសម្ព័ន្ធ[2] ដូចក្នុងសេចក្តីថ្លែងការណ៍អំពីគោលនយោបាយការពារសុវត្ថិភាពរបស់ធនាគារ ឲ្យស្របនឹងអនុសាសន៍នៃរបាយការណ៍ពិគ្រោះសាយោបល់ផ្នែកបច្ចេកទេសដែលអនុវត្តជាផ្នែកមួយនៃគម្រោងនេះ (ឆ្នាំ២០១២)។ ដោយទំនប់ Xekaman 1 - ជាគម្រោងតែមួយគត់ស្ថិតនៅក្រោមការសាងសង់ដែលពាក់ព័ន្ធនឹងបណ្តាញបញ្ជូនថាមពលនេះ បំពានយ៉ាងខ្លាំងលើគោលការណ៍ការពារសុវត្ថិភាពរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ដោយបានផ្តល់ហិរញ្ញប្បទានពីធនាគារអភិវឌ្ឍន៍អាស៊ីសម្រាប់គម្រោងអន្តរបណ្តាញថាមពលអគ្គិសនី Hatxan-Pleiku។ បណ្តាបញ្ហានៅការដ្ឋានទំនប់វារីអគ្គិសនី Xekaman 1 ដែលអង្គការទន្លេអន្តរជាតិ និងអ្នកពិគ្រោះយោបល់ផ្ទាល់របស់ធនាគារអភិវឌ្ឍន៍អាស៊ី បានចងក្រងជាឯកសារ រួមមាន៖

- គ្មានការប្រកាសជាសាធារណៈអំពីការវាយតម្លៃផលប៉ះពាល់បរិស្ថាន និងផែនការតាំងលំនៅថ្មី,
- ពុំបានផ្តល់ព័ត៌មានជាផ្លែផ្កាអំពីគម្រោងទៅអ្នកភូមិដែលទទួលរងផលប៉ះពាល់ដោយសារគម្រោង គឺអ្នកភូមិជនជាតិដើមភាគតិចអាឡាក់ (Alak) និង ចេះ (Jeh) ទាំងអស់,
- អ្នកភូមិដែលបានរស់នៅក្នុងស្ថានភាពមិនច្បាស់លាស់អស់រយៈពេលជាងមួយទសវត្សរ៍មក ហើយ នៅក្នុង "ទីតាំងលំនៅបណ្តោះអាសន្ន" ចល័តនៅជិតតំបន់សំណង់ដោយគ្មានហេដ្ឋារចនាសម្ព័ន្ធជាមូលដ្ឋាន ឬគ្មានព័ត៌មានអំពីពេលវេលាដែលប្រជាជននឹងរុះរើ,
- គ្មានការកំណត់ទីតាំងលំនៅថ្មីសមរម្យ ដោយតំបន់ដែលបានស្នើឡើងដោយអ្នកគាំទ្រគម្រោង មានទីតាំងស្ថិតនៅជិតចម្ការកៅស៊ូមួយកន្លែង ហើយជម្រើសនៃការប្រកបរបរចិញ្ចឹមជីវិតមានកម្រិត គឺគ្មានអ្វីផ្សេងទៀតក្រៅពីការងារពាក់ព័ន្ធនឹងចម្ការកៅស៊ូនោះទេ,
- គ្មានភស្តុតាងបញ្ជាក់អំពីការវាយតម្លៃផលប៉ះពាល់បរិស្ថាន ឬផលប៉ះពាល់កើនបន្ថែមឆ្លងដែន, និង
- គ្មានវិធានការកាត់បន្ថយការបាត់បង់ជីវចម្រុះឡើយ។



នៅពេលដែលសកម្មភាពសាងសង់ទំនប់វារីអគ្គិសនី Xekaman 1 បានចាប់ផ្តើមជាងមួយទសវត្សរ៍កន្លងទៅនោះ គ្រួសារនេះបានផ្លាស់ប្តូរទៅទីតាំងលំនៅថ្មីជាបណ្តោះអាសន្នដោយពុំមានសេវាហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន រួមទាំងបណ្តាញទឹកស្អាតផង។ ដោយសារលក្ខខណ្ឌនៅទីតាំងរស់នៅបណ្តោះអាសន្ននោះ ពុំមានភាពល្អប្រសើរច្រើនឆ្នាំកន្លងទៅនេះ ថែមទាំងពួកគាត់មិនទាន់បានទទួលសំណងតាំងលំនៅថ្មីណាមួយ ដូច្នេះពួកគាត់សម្រេចចិត្តដោយខ្លួនឯងក្នុងការផ្លាស់ទៅរកទីតាំងដីដែលពួកគាត់បានកំណត់ថាសមស្របសម្រាប់បង្កបង្កើនផល និងរកអនុផលព្រៃឈើ។ ទោះជាយ៉ាងនេះក្តី ដោយសារតែពួកគាត់គ្មានប័ណ្ណកម្មសិទ្ធិដីធ្លីនៅទីតាំងថ្មីនោះ ដូច្នេះពួកគាត់រស់នៅដោយភ័យខ្លាចជាប្រចាំ មិនដឹងថា ពួកគាត់ត្រូវគេបណ្តេញចេញពីដីនោះនៅពេលណា។

សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅមើលតាមអាសយដ្ឋាននេះ http://www.internationalrivers.org/node/7730

1 Ziv et al. "ការធ្វើឲ្យមានតុល្យភាពជីវចំរុះត្រី សន្តិសុខស្បៀង និងថាមពលវារីអគ្គិសនីនៅក្នុងអាងទន្លេមេគង្គ" របាយការណ៍អង្គប្រជុំរបស់បណ្ឌិតសភាវិទ្យាសាស្ត្ររបស់សហរដ្ឋអាមេរិក (ក្បាល១០៩, លេខ១៥) ឆ្នាំ២០១២។

2 ប្រសិនបើ គម្រោងទាំងនោះពឹងផ្អែកទៅលើ "ស្ថានីយសម្ព័ន្ធ" ឲ្យដំណើរការ (ឧ៖ ខ្សែបណ្តាញនិងគម្រោងវារីអគ្គិសនី) ដូច្នេះ "ស្ថានីយសម្ព័ន្ធ" ដែលបានកំណត់រួចហើយនោះ ត្រូវតែអនុវត្តតាមលិខិតបទដ្ឋានបរិស្ថាននិងសង្គមដូចមានចែងនៅក្នុងគោលការណ៍ការពារសុវត្ថិភាពរបស់ធនាគារអភិវឌ្ឍន៍អាស៊ី មុនពេលដែលការផ្តល់ហិរញ្ញប្បទានសម្រាប់គម្រោងត្រូវបានអនុម័ត។

# លេខគម្រោង 41924–014៖ គម្រោងវារីអគ្គិសនី NAM NGIEP 1



ប្រជាជនដែលរស់នៅតាមទន្លេ Nam Ngiep ពឹងផ្អែកលើទន្លេនេះដើម្បីប្រកបរបរចិញ្ចឹមជីវិត និងដឹកជញ្ជូន។

## ស្ថានភាព៖ អនុម័តនៅឆ្នាំ២០១៤

## ការសាងសង់កំពុងដំណើរការ

គម្រោងវារីអគ្គិសនី Nam Ngiep 1 ដែលមានកម្លាំង ២៩០ មេហ្គាវ៉ាត់ នៅក្នុងប្រទេសឡាវ កំពុងដំណើរការសាងសង់ដោយក្រុមហ៊ុនអគ្គិសនី Nam Ngiep 1 ជាសម្ព័ន្ធក្រុមហ៊ុនដែលមានក្រុមហ៊ុន Power Electric Kansai របស់ប្រទេសជប៉ុន (៤៥%) ក្រុមហ៊ុន EGAT International របស់ប្រទេសថៃ (៣០%) និងសហគ្រាសរដ្ឋរបស់ប្រទេសឡាវ (២៥%)។ ទឹកប្រាក់ច្រើនជាង២២០លានដុល្លារអាមេរិក ត្រូវបានផ្តល់ជូនជាប្រាក់កម្ចីពីធនាគារអភិវឌ្ឍន៍អាស៊ី ព្រមទាំងទឹកប្រាក់ជិត២០០លានដុល្លារអាមេរិក ពីធនាគារជប៉ុនសម្រាប់កិច្ចសហប្រតិបត្តិការអន្តរជាតិ (JBIC)។ អគ្គិសនីច្រើនជាង៩០% ដែលផលិតបាននឹងត្រូវនាំចេញទៅប្រទេសថៃ។ ប្រជាជនជាង៣០០០នាក់ ដែលភាគច្រើនជាគ្រួសារពលរដ្ឋជនជាតិដើមភាគតិចម៉ុង (Hmong) និង ឃ្មុ (Khmu) ត្រូវតែរុះរើទៅតាំងទីលំនៅថ្មី ដើម្បីបើកផ្លូវសម្រាប់គម្រោងនេះ។ ដោយយោងលើការរឹតបន្តឹងនយោបាយនាពេលបច្ចុប្បន្ននៅក្នុងប្រទេសឡាវ ប្រជាជនដែលរងផលប៉ះពាល់គ្មានវិធីក្នុងការរាយការណ៍អំពីការតវ៉ាណាមួយដោយមិនប្រឈមនឹងលទ្ធភាពនៃការស្តីបន្ទោសចំពោះការសួរនាំអំពី ឬការរិះគន់លើការសម្រេចចិត្តស្តីពីគម្រោងអភិវឌ្ឍន៍ដោយរដ្ឋាភិបាលឡើយ ជាពិសេសមិនអាចនិយាយថា យល់ស្រប ឬមិនយល់ស្របជាមួយនឹងការសាងសង់គម្រោងទំនប់នោះបានឡើយ។

ការរំលោភបំពានលើគោលការណ៍ការពារសុវត្ថិភាពរបស់ធនាគារអភិវឌ្ឍន៍អាស៊ីនៅទំនប់ Nam Ngiep 1 រួមមាន៖

- ខ្វះព័ត៌មានសម្រាប់ការស្វែងយល់អំពីផលប៉ះពាល់សង្គមនិងបរិស្ថានដោយសារទំនប់ អំពីផែនការតាំងលំនៅថ្មី និងអំពីពេលវេលាដែលត្រូវផ្តល់ជូនប្រជាជនដែលទទួលរងផលប៉ះពាល់,
- ខ្វះអត្រាដែលបញ្ជាក់ច្បាស់លាស់អំពីការផ្តល់ប្រាក់សំណង ព្រមទាំងគ្មានការយល់ព្រមទៅលើអ្វីដែលមានលក្ខណៈសម្បត្តិជាតម្លៃដោះដូរសម្រាប់ការបាត់បង់ ទោះបីជា ការងារត្រៀមបម្រុងរបស់គម្រោងកំពុងដំណើរការក៏ដោយ,
- ខ្វះការពិគ្រោះយោបល់ប្រកបដោយផ្លែផ្កា និងឯកភាពយល់ព្រមដោយគ្មានការបង្ខិតបង្ខំពីប្រជាជនដែលរងផលប៉ះពាល់ក្នុងការផ្លាស់ប្តូរទីតាំង ឬចាកចេញពីដីធ្លី,
- ខ្វះដីសមប្រកប នៅក្នុងតំបន់តាំងទីលំនៅថ្មីដែលបានកំណត់ (ដែល៧០% ជាតំបន់ព្រៃការពារវ៉ែ), និង
- គ្មានការវាយតម្លៃផលប៉ះពាល់បន្ថែមឲ្យបានទូលំទូលាយនិងហ្មត់ចត់ គ្មានការវាយតម្លៃគ្រោះថ្នាក់ធំៗ និងគ្មានផែនការកាត់បន្ថយផលប៉ះពាល់ ឬគ្មានធ្វើបច្ចុប្បន្នភាពការវាយតម្លៃវិធានការសមស្របនៅខ្សែទឹកខាងក្រោម ដែលជាហេតុផលសម្រាប់ការសាងសង់ទំនប់វារីអគ្គិសនីខ្សែទឹកខាងលើ។

លើសពីនេះទៅទៀត "ការរៀបចំប្រព័ន្ធជីវៈចម្រុះ" សមស្របសម្រាប់ទំនប់ Nam Ngiep 1 មិនទាន់ត្រូវបានកំណត់នៅឡើយ។ ដោយផ្អែកលើឯកសារនិងការស្រាវជ្រាវដែលបានធ្វើឡើងដោយក្រុមបរិស្ថានអន្តរជាតិមួយចំនួន, រួមទាំងសហភាពអន្តរជាតិដើម្បីអភិរក្សធម្មជាតិ (IUCN) ផងវាគួរឲ្យឆ្ងល់ថា តើទីតាំងជីវៈចម្រុះដែលបានកំណត់នោះអាចឈានដល់លទ្ធផល "គ្មានការខាតបង់ធំដុំ (ដូចដែលបានលើកឡើងដោយអ្នកគាំទ្រគម្រោងនេះ) ដើម្បីជំនួសការបាត់បង់ជម្រកសត្វព្រៃនិងតំបន់ព្រៃយ៉ាងសំខាន់ដែលបណ្តាលមកពីគម្រោងនោះដែរឬយ៉ាងណា។ នៅក្នុងករណីពិសេសពាក់ព័ន្ធនឹងទំនប់ Nam Ngiep 1 តាមការសិក្សាជាមូលដ្ឋាននានាមុនការងាររៀបចំត្រៀម មិនត្រូវបានបញ្ចប់ទេ ជាហេតុនាំឱ្យមានការគណនាមិនពិត ឬមិនត្រឹមត្រូវអំពីតម្លៃជីវចម្រុះមុន គម្រោង។

សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅមើលតាមអាសយដ្ឋាននេះ http://www.internationalrivers.org/node/8372

# គម្រោងលេខ 37734–032៖ គម្រោងវារីអគ្គិសនីណាំធឿន២



ខ្សែទឹកផ្នែកខាងក្រោមនៃទំនប់ណាំធឿន២ នៅតាមបណ្តោយទន្លេ Xe Bang Fai ច្រាំងទន្លេបន្តបាក់ ដែលបណ្តាលឱ្យប្រជាជនបាត់បង់ដីដែលមានតម្លៃ ដែលពីមុនពួកគាត់ប្រើប្រាស់ជាដីកសិកម្ម។ ទឹកទន្លេនៅតែល្អក់ ធ្វើឱ្យមានការលំបាកក្នុងការរកត្រី (នេសាទត្រី) និងប្រភេទសត្វក្នុងទឹកផ្សេងៗទៀត ដែលគេពឹងផ្អែកជាប្រភពអាហារមានប្រូតេអ៊ីនយ៉ាងសំខាន់។

## ស្ថានភាព៖ អនុម័តនៅឆ្នាំ២០០៥

**ទំនប់វារីអគ្គិសនីណាំធឿន២**ដែលមានកម្លាំង ១.០៧០ មេហ្គាវ៉ាត់ ត្រូវគាំទ្រផ្នែកហិរញ្ញវត្ថុដោយធនាគារអភិវឌ្ឍន៍អាស៊ី ធនាគារពិភពលោក និងធនាគារវិនិយោគអឺរ៉ុប។ គម្រោងនេះបានចាប់ផ្តើមដំណើរការនៅឆ្នាំ២០១០ ដោយធ្វើឲ្យប្រជាជនដែលជាជនជាតិដើមភាគតិចច្រើនជាង ៦.៣០០ គ្រួសារ ត្រូវផ្លាស់ប្តូរទីតាំងដើម្បីយកដីធ្វើអាងទឹកទំហំ៤៥០គម² និងបណ្តាលឲ្យប៉ះពាល់ប្រជាជននៅខ្សែទឹកខាងក្រោមច្រើនជាង ១១០.០០០ នាក់។

ទោះបីជា គម្រោងនេះត្រូវបានកំណត់ថា ជាគម្រោងសំខាន់បំផុតដោយស្ថាប័នហិរញ្ញវត្ថុអន្តរជាតិនានា និងបង្ហាញថាទំនប់វារីអគ្គិសនីយ៉ាងធំនេះ អាចផ្តល់ថាមពលសមស្របក៏ដោយ ក៏ផលចំណេញដែលបានសន្យានោះ នៅតែលំបាកសម្រេច។ ផលប៉ះពាល់ខ្លះត្រូវបានកត់ត្រា ដោយក្រុមជំនាញហិរញ្ញប្បទានធនាគារអភិវឌ្ឍន៍អាស៊ី និងធនាគារពិភព, ដែលជាក្រុមប្រឹក្សាពិនិត្យឡើងវិញផ្នែកបច្ចេកទេសរបស់ស្ថាប័នផ្តល់ប្រាក់កម្ចី ក៏ដូចជា កំណត់ត្រាក្នុងអំឡុងពេលចុះទស្សនកិច្ចដោយអង្គការទន្លេអន្តរជាតិ និងអង្គការឃ្លាំមើលទន្លេមេគង្គដែរ។

ផលប៉ះពាល់ទាំងនោះមានដូចជា៖

- ខ្វះការងារដែលមាននិរន្តរភាពនិងលទ្ធភាពប្រើប្រាស់ធនធានសម្រាប់ប្រជាជនដែលតាំងទីលំនៅថ្មី,
- ដីមានគុណភាពមិនល្អ និងលទ្ធភាពនៃការបង្កបង្កើនផលសម្រាប់ធ្វើជាអាហារនិងសម្រាប់លក់នៅតំបន់តាំងទីលំនៅថ្មីមានកម្រិត,[3]
- ការពឹងផ្អែកទាំងស្រុងរបស់ប្រជាជនដែលត្រូវផ្លាស់ប្តូរទីតាំងដោយសារគម្រោងលើការជួញដូរសត្វព្រៃ និងឈើខុសច្បាប់ដែលរកប្រាក់បានច្រើននៅក្នុងតំបន់ការពារ សម្រាប់ចាយវាយលើតម្រូវការចាំបាច់ប្រចាំថ្ងៃ,
- ការស្តារប្រាក់ចំណូល និងជីវភាពរស់នៅឡើងវិញសម្រាប់បណ្តាសហគមន៍នៅខ្សែទឹកខាងក្រោមធ្វើមិនបានសម្រេច ដូចលក្ខខណ្ឌតម្រូវនៅក្នុងកិច្ចព្រមព្រៀងសម្បទាន (វាយតម្លៃដោយក្រុមប្រឹក្សាពិនិត្យឡើងវិញផ្នែកបច្ចេកទេសរបស់ស្ថាប័នផ្តល់ប្រាក់កម្ចី (LTA) នៅខែធ្នូ ឆ្នាំ២០១៤),
- ការបាត់បង់យ៉ាងច្រើននូវសន្តិសុខសេដ្ឋកិច្ចសម្រាប់ប្រជាជនរស់នៅផ្នែកខ្សែទឹកខាងក្រោមដោយសារការបំផ្លាញជម្រកត្រីធម្មជាតិ (ការពិនិត្យតាមដានរបស់ក្រុមហ៊ុនបង្ហាញឱ្យឃើញនូវការថយចុះបរិមាណត្រីក្នុងរយៈពេលវែង), ដោយសារទឹកជន់លិចដីស្រែទំនាប និងការលិចលង់សួនដំណាំនៅតាមមាត់ទន្លេដែលប្រជាជនប្រើសម្រាប់បង្កបង្កើនផលសម្រាប់ធ្វើជាអាហារ, និង
- ប្រជាពលរដ្ឋដែលរងផលប៉ះពាល់ចំនួន៦៧ភូមិស្ថិតនៅខ្សែទឹកខាងក្រោម ខ្វះលទ្ធភាពទទួលបាននូវកម្មវិធីរបរចិញ្ចឹមជីវិត ដែលពួកគាត់ត្រូវបានគេផ្តល់សំណងជូនជាសាច់ប្រាក់តែម្តងប៉ុណ្ណោះ។

ជាទូទៅ ដោយសារតែលទ្ធផលមិនគ្រប់គ្រាន់ពីកម្មវិធីកាត់បន្ថយផលប៉ះពាល់ទាំងនេះ ដូច្នេះការកំណត់អត្រាគម្រោងដោយធនាគារពិភពលោក នៅតែ "មិនជាទីគាប់ចិត្តសមល្មម" នៅឡើយ។ បន្ថែមលើសនេះទៀត តាមការសិក្សានាពេលថ្មីៗពាក់ព័ន្ធនឹងទំនប់ណាំធឿន២ ហើយដែលត្រូវបានចេញផ្សាយនៅក្នុងទស្សនាវដ្តីសិក្សា Biogeosciences (ខែសីហា ឆ្នាំ២០១៤) បានសន្និដ្ឋានថា ការបំភាយឧស្ម័នកាបោនឌីអុកស៊ីដពីអាងស្តុកទឹក ត្រូវបានវាយតម្លៃមិនគ្រប់ជ្រងជ្រោយ ហើយសមតែទទួលបានការយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើវដ្តជីវិតរបស់គម្រោង ដែលផ្ទុយទៅនឹងការសន្មតដែលថា គម្រោងវារីអគ្គិសនីគឺជាប្រភពនៃថាមពលបៃតង។

សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅមើល តាមអាសយដ្ឋាននេះ
http://www.internationalrivers.org/node/2337

3 យោងតាម NTPC (ដូចបានដកស្រង់បញ្ចូលទៅក្នុងរបាយការណ៍របស់ក្រុមប្រឹក្សាពិនិត្យឡើងវិញផ្នែកបច្ចេកទេសរបស់ស្ថាប័នផ្តល់ប្រាក់កម្ចី (LTA) [ខែធ្នូ ឆ្នាំ២០១៤]) បានឲ្យដឹងថា មកដល់ត្រឹមខែឧសភា ឆ្នាំ២០១៤ ប្រជាជនដែលតាំងលំនៅថ្មី៨២% មិនប្រើប្រាស់ដីដែលគេចែកឲ្យពួកគាត់នោះទេ។

# ផែនការនិងក្របខ័ណ្ឌយុទ្ធសាស្ត្ររបស់មហាអនុតំបន់ទន្លេមេគង្គ

កម្មវិធីមហាអនុតំបន់ទន្លេមេគង្គ ដែលចាប់ផ្ដើមដំណើរការនៅឆ្នាំ១៩៩២ ចាត់អាទិភាពលើការសាងសង់បង្គោលបណ្ដាញអគ្គិសនីក្នុងតំបន់ ដែលអាចនាំយកអគ្គិសនីដែលផលិតឡើងដោយទំនប់វារីអគ្គិសនីពីទំនប់ទន្លេនៅតំបន់ជនបទនៃប្រទេសមួយ ទៅស្ថានីយនានានៅទីក្រុង និងមជ្ឈមណ្ឌលផលិតកម្មនៅកន្លែងផ្សេងទៀត។ ប៉ុន្តែ ភាគច្រើននៃប្រជាជន៣២៦លាននាក់នៃតំបន់នេះ ខ្វះព័ត៌មានជាមូលដ្ឋានអំពីថា តើផែនការសម្រាប់មហាអនុតំបន់ទន្លេមេគង្គនេះត្រូវបានធ្វើឡើងដោយរបៀបណា តើមានអ្វីខ្លះនៅក្នុងផែនការទាំងនេះ ដែលជាការទទួលខុសត្រូវរបស់អ្នកធ្វើសេចក្ដីសម្រេច, ថាតើត្រូវធ្វើដូចម្ដេចដើម្បីឲ្យអ្នកធ្វើសេចក្ដីសម្រេចនោះចេះទទួលខុសត្រូវ និងខ្វះព័ត៌មានពាក់ព័ន្ធនឹងយន្តការសម្រាប់ការស្វែងរកដំណោះស្រាយបណ្ដឹង។ ការវាយតម្លៃជម្រើស សិក្សាលទ្ធភាពអនុវត្ត និងការវាយតម្លៃផលប៉ះពាល់បរិស្ថាននិងសង្គមដោយសារគម្រោងវិនិយោគថាមពលរបស់មហាអនុតំបន់ទន្លេមេគង្គ ជាទូទៅប្រជាជនម្ចាស់ស្រុកដែលទទួលរងផលប៉ះពាល់ មិនទទួលបានព័ត៌មានទាំងនោះទេ។

តំណាងរដ្ឋាភិបាលមកពីប្រទេសនីមួយៗនៃតំបន់ទន្លេមេគង្គ បានឯកភាពគ្នាលើផែនការនិងក្របខ័ណយុទ្ធសាស្ត្រថាមពលក្នុងតំបន់ដែលអំពាវនាវឲ្យមានការអភិវឌ្ឍគម្រោងផលិកម្មថាមពលខ្នាតធំ ជាពិសេសទំនប់វារីអគ្គិសនី ដើម្បីផ្ដល់សុវត្ថិភាពថាមពល តាមរយៈប្រព័ន្ធអន្តរបណ្ដាញអគ្គិសនី។ ជាលទ្ធផលនៃផែនការទាំងនេះ គម្រោងទំនប់វារីអគ្គិសនីធំៗ ត្រូវបានស្នើឡើងដើម្បីសាងសង់នៅតាមទន្លេរបស់ប្រទេសឡាវ ភូមា (មីយ៉ាន់ម៉ា) និងប្រទេសកម្ពុជា ដើម្បីផ្គត់ផ្គង់អគ្គិសនីទៅទីក្រុង នៅប្រទេសថៃ វៀតណាម និងប្រទេសចិនតាមរយៈខ្សែបណ្ដាញបញ្ជូនអគ្គិសនីតង់ស្យុងខ្ពស់។

គំរូនេះត្រូវបានសន្មត់ថា៖

- ចំណាយមានប្រសិទ្ធភាព ដូច្នេះប្រទេសដែលមានតម្រូវការថាមពលខ្ពស់អាចមានលទ្ធភាពទទួលបានអគ្គិសនីដែលមានតម្លៃទាប,
- នាំយកថាមពលអគ្គិសនីពី បណ្ដាប្រទេស "សម្បូរធនធានវារីអគ្គិសនី" ទៅប្រទេសផ្សេងៗទៀតដែលមានតម្រូវការថាមពលអគ្គិសនីកាន់តែច្រើន,
- ទទួលផលចំណេញផ្សេងៗ នៅពេលមានបន្ទុកខ្ពស់ និង/ឬ នៅពេលបម្រែបម្រួលបន្ទុកខ្ពស់តាមរដូវ,
- នាំមកនូវភាពទុកចិត្តលើអគ្គិសនីកាន់តែប្រសើរឡើង និងចំណាយលើថាមពលអគ្គិសនីក្នុងតម្លៃកាន់តែទាប, និង
- នាំមកនូវរូបិយប័ណ្ណបរទេសចូលទៅក្នុងតំបន់ ជាពិសេសនៅក្នុងតំបន់ដែលមិនទាន់មានការអភិវឌ្ឍច្រើន តាមរយៈស្វយសារ និងការវិនិយោគផ្ទាល់ពីបរទេស។

ក្របខ័ណ្ឌមួយដែលកំណត់អាទិភាពលើគម្រោងវារីអគ្គិសនីធំៗ ដើម្បីផ្គត់ផ្គង់អគ្គិសនីសម្រាប់បណ្ដាញអគ្គិសនីឆ្លងដែន ត្រូវបានស្នើឡើង ដែល៖

- មិនគិតពិចារណាលើបណ្ដាគន្លងដែលផ្អែកលើវិធីសាស្ត្រផ្ទុកជាក់ស្ដែងពីក្រោមឡើងលើ ដែលតាមដាននិន្នាការពិតប្រាកដក្នុងការប្រើប្រាស់ថាមពល,[4]
- មិនបានពិចារណាអំពីវិសាលភាពនៃជម្រើសឲ្យបានពេញលេញ សម្រាប់បច្ចេកវិទ្យាកកើតឡើងវិញដែលធានានិរន្តរភាពបរិស្ថាន រួមទាំងផលិតកម្មថាមពលខ្នាតតូច និងថាមពលវិមជ្ឈការ,




ផែនទីនៃអន្តរបណ្ដាញអគ្គិសនីបច្ចុប្បន្ន និងផែនការរបស់មហាអនុតំបន់ទន្លេមេគង្គ។ ប្រភពផែនទីបរិស្ថានរបស់មហាអនុតំបន់ទន្លេមេគង្គ។ ខែតុលា ឆ្នាំ២០១៣ <www.gms-eoc.org>

4 មានការទទួលស្គាល់យ៉ាងទូលំទូលាយថា បណ្ដាផែនការអភិវឌ្ឍថាមពលនៅក្នុងតំបន់ត្រូវបានវាយតម្លៃមិនគ្រប់ជ្រុងជ្រោយជាប្រព័ន្ធដោយក្រុមហ៊ុនអគ្គិសនីរដ្ឋ។ ឧទាហរណ៍ នៅប្រទេសថៃ បណ្ដាផែនការអភិវឌ្ឍន៍ថាមពល គឺផ្អែកលើការសន្មតអំពីកំណើននិទស្សន្ត, គឺមិនផ្អែកលើបែបផែនប្រវត្តិនៃកំណើនបន្តបន្ទាប់ និងលើសំណើដែលឆ្លើយតបទៅនឹងការកើនឡើងនូវតម្រូវការថាមពលដោយការសាងសង់រោងចក្រថាមពលថ្មីខ្នាតធំៗទេ។ វិធីអនុវត្តអន្តរជាតិល្អបំផុតបង្ហាញថា មានបណ្ដាជម្រើសផ្សេងៗ ទៀតដែលអាចមានតម្លៃថោកជាងប្រឈមគ្រោះថ្នាក់តិចជាង និងកាត់បន្ថយផលប៉ះពាល់សុខភាព និងបរិស្ថានឲ្យថយចុះដល់កម្រិតទាបបំផុត។ សូមមើលជាឧទាហរណ៍៖ "សំណើផែនការអភិវឌ្ឍន៍ថាមពលអគ្គិសនី ឆ្នាំ២០១២ និងក្របខ័ណ្ឌសម្រាប់បង្កើនគណនេយ្យភាព និងការងារធ្វើផែនការវិស័យថាមពល" <http://www.internationalrivers.org/files/attached-files/pdp2012-eng_1.pdf>.

- ខកខានមិនបានបញ្ចូលការវាយតម្លៃផលប៉ះពាល់បរិស្ថាននិងសង្គមដែលកើតមាន,
- មិនផ្អែកលើមូលដ្ឋានសេណារីយ៉ូចំណាយពិតតិច ដែលបញ្ចូលចំណាយលើបរិស្ថាននិងសង្គម។ ផ្ទុយទៅវិញ ហានិភ័យទាំងនេះកំពុងកើតមានលើប្រជាជននៅក្នុងតំបន់ដែលមានជីវភាពរស់នៅពឹងផ្អែកយ៉ាងខ្លាំងលើការនេសាទត្រីធម្មជាតិ និងការធ្វើស្រែ ដែលមុខរបរទាំងពីរនេះ ត្រូវទទួលរងផលប៉ះពាល់ដោយសារគម្រោងទំនប់វារីអគ្គិសនីខ្នាតធំទាំងនេះ;[5] និង
- ចងភ្ជាប់តំបន់ឲ្យពឹងអាស្រ័យតែលើទំនប់វារីអគ្គិសនីធំៗ នៅពេលដែលការប្រែប្រួលអាកាសធាតុតម្រូវឱ្យមានវិធីដោះស្រាយបត់បែនកាន់តែច្រើនដែលបញ្ចូលនូវជម្រើសច្រើនដើម្បីបំពេញតម្រូវការរបស់ប្រជាជន។

## ស្ថាប័នឈានមុខដែលជំរុញបណ្តាផែនការថាមពលមហាអនុតំបន់ទន្លេមេគង្គ

ការដឹកនាំក្នុងការអនុវត្តផែនការវិស័យថាមពលមហាអនុតំបន់ទន្លេមេគង្គឲ្យដំណើរការទៅមុខ និងវិធានជាក់លាក់សម្រាប់គ្រប់គ្រងពាណិជ្ជកម្មថាមពលនៅក្នុងតំបន់ ត្រូវបានផ្តល់ជូនដោយគណៈកម្មាធិការមួយដែលតំណាងក្រសួងថាមពលរបស់ប្រទេសរៀងៗខ្លួន (គណៈកម្មាធិការសម្របសម្រួលពាណិជ្ជកម្មថាមពលតំបន់) ដែលត្រូវកោះប្រជុំ និងសម្របសម្រួលដោយធនាគារអភិវឌ្ឍន៍អាស៊ី។ បណ្តាគម្រោងថាមពលដែលគេបានជ្រើសរើសជាវិស័យអាទិភាពកម្រិតខ្ពស់សម្រាប់ការវិនិយោគរវាងឆ្នាំ២០១៤ និងឆ្នាំ២០១៨ រួមមានគម្រោងអភិវឌ្ឍន៍ៈ

- អន្តរបណ្តាញថាមពលអគ្គិសនីឡាវ - វៀតណាម (Hatxan - Pleiku) ដើម្បីបញ្ជូនអគ្គិសនីកម្លាំង ១.០១៣ មេហ្គាវ៉ាត់ (MW) ដែលផលិតដោយទំនប់វារីអគ្គិសនីមួយចំនួន នៅអាំងទន្លេសេកុង ប្រទេសឡាវទៅប្រទេសវៀតណាម (គម្រោង REG-ENG-01), និង
- អនុស្ថានីយបញ្ជូនអគ្គិសនី Nabong 500 kV ដើម្បីនាំថាមពលអគ្គិសនីចេញពីទំនប់ Nam Ngiep 1 ណាំងៀន 1 និង Nam Ngum 2 នៅក្នុងប្រទេសឡាវទៅប្រទេសថៃ (គម្រោង REG-ENG-02) ។

បន្ថែមលើនេះទៀត នឹងមានការសិក្សាដើម្បីៈ

- បង្កើតមជ្ឈមណ្ឌលសម្របសម្រួលថាមពលអគ្គិសនីប្រចាំតំបន់ដើម្បីជំរុញនិងលើកកម្ពស់បទដ្ឋានការងារ កូដបង្គោលភ្លើង និងវិធានទីផ្សារឲ្យត្រូវគ្នា។

## ការសិក្សាដែលចាត់ចែងដោយធនាគារអភិវឌ្ឍន៍អាស៊ីៈ អនុសាសន៍ត្រូវទម្លាក់ចោល?

ការសិក្សាជំនួយបច្ចេកទេសសំខាន់ៗដែលអនុវត្តសម្រាប់កម្មវិធីមហាអនុតំបន់ទន្លេមេគង្គ គូសបញ្ជាក់អំពីភាពចាំបាច់ដើម្បីប្តូរទៅរកអនាគតដោយផ្តោតកាន់តែខ្លាំងលើប្រសិទ្ធភាពថាមពល និងជម្រើសថាមពលកកើតឡើងវិញ និងផ្តល់អនុសាសន៍ច្បាស់លាស់ដើម្បីជៀសវាងការពឹងផ្អែកខ្លាំងលើវារីអគ្គិសនីខ្នាតធំ។ ទោះបីជាមានការរកឃើញតាមរយៈការស្រាវជ្រាវនោះក៏ដោយ ក៏បណ្តាអាទិភាពវិស័យថាមពលរបស់កម្មវិធីមហាអនុតំបន់មេគង្គនៅតែមិនផ្លាស់ប្តូរដដែល។

ឧទាហរណ៍ នៅពាក់កណ្តាលឆ្នាំ២០១៣ ធនាគារអភិវឌ្ឍន៍អាស៊ីបានចេញផ្សាយការវាយតម្លៃអំពីការអភិវឌ្ឍវិស័យថាមពលមហាអនុតំបន់ទន្លេមេគង្គៈ <u>វឌ្ឍនភាព រំពឹងទុក និងអាទិភាពនៃការវិនិយោគក្នុងតំបន់</u> ដែលវិភាគលើផែនការអភិវឌ្ឍថាមពលជាតិ និងវិនិយោគក្នុងតំបន់។[6]

របាយការណ៍នេះបានព្រមានថា ផលប៉ះពាល់ដោយសាររោងចក្រផលិតថាមពលនិងបណ្តាញអគ្គិសនី លើផ្នែកបរិស្ថាននិងសហគមន៍មានសភាពធ្ងន់ធ្ងរ និងថា ការព្រួយបារម្ភទាំងនេះតម្រូវឲ្យមាន "ការយកចិត្តទុកដាក់ក្នុងកម្រិតដែលមិនអាចកើតមាន" ពីខាងរដ្ឋាភិបាល ឬអ្នកគាំទ្រគម្រោងនេះ។ របាយការណ៍នេះបានផ្តល់អនុសាសន៍ថា បណ្តាប្រទេសពាក់ព័ន្ធគប្បីត្រូវជំរុញបណ្តាគោលដៅឆ្ពោះទៅរកពេលវេលាសម្រាប់ការកែលម្អប្រសិទ្ធផលថាមពល និងសម្រាប់ថាមពលកកើតឡើងវិញ។ លើសពីនេះទៅទៀត នៅខែធ្នូ ឆ្នាំ២០១៣ ការវាយតម្លៃជាយុទ្ធសាស្ត្រអំពីបរិស្ថាន (SEA) ដែលចាត់ចែងដោយធនាគារអភិវឌ្ឍន៍អាស៊ីក្រោមមានចំណងជើងថា ការធានានិរន្តរភាពនៃការអភិវឌ្ឍថាមពលតំបន់មហាអនុតំបន់ទន្លេមេគង្គ[7] ត្រូវបញ្ចប់។ របាយការណ៍នេះបានវាយតម្លៃគំរូនៃផែនការអភិវឌ្ឍន៍ថាមពលជាតិបច្ចុប្បន្ន (PDPs) របស់ប្រទេសកម្ពុជា ឡាវ ថៃ និងវៀតណាម ដោយប្រៀបធៀបទៅនឹងសេណារីយោជម្រើសពីរគឺ ផែនការថាមពលកកើតឡើងវិញ និងផែនការអគ្គិសនីប្រសិទ្ធផលថាមពល។ របាយការណ៍នេះរកឃើញនូវបញ្ហាធំៗជាមួយនឹងផែនការអភិវឌ្ឍន៍ថាមពលបច្ចុប្បន្នដែលបានដាក់ឲ្យអនុវត្ត រួមមានដូចជាៈ

- ផែនការអភិវឌ្ឍន៍ថាមពលរបស់ប្រទេសឡាវ និងប្រទេសកម្ពុជាបញ្ចូលគម្រោងវារីអគ្គិសនីមួយចំនួនដែលកំណត់ថា ផលិតថាមពលក្នុងបរិមាណច្រើនសម្រាប់នាំចេញនោះ មិនត្រូវគ្នានឹងបណ្តាគម្រោងនាំចេញដូចគ្នានៅក្នុងផែនការអភិវឌ្ឍន៍ថាមពលសម្រាប់ប្រទេសថៃ និងវៀតណាមទេ,
- គម្រោងប៉ាន់ស្មានថ្នាក់ជាតិអំពីសមត្ថភាពដែលត្រូវការ និងអំពីកំណើនតម្រូវការមានកម្រិតខ្ពស់មិនសមហេតុផល ដែលជាហេតុនាំឱ្យមានការប៉ាន់ប្រមាណមិនត្រឹមត្រូវអំពីចំនួន និងទំហំនៃគម្រោងថាមពលដែលត្រូវការ, និង
- រោងចក្រថាមពលអគ្គិសនីថ្មីៗជាច្រើន (នុយក្លេអ៊ែរ និងវារីអគ្គិសនី) ដែលត្រូវបានស្នើឡើងនោះ មិនចាំបាច់ត្រូវសាងសង់ទេ ប្រសិនបើវិធានការប្រសិទ្ធផលថាមពលត្រូវបានអនុវត្ត បណ្តាគម្រោងថាមពលកកើតឡើងវិញដែលមាននិរន្តរភាពត្រូវបានចាត់ជាអាទិភាព និងគន្លងតម្រូវការថាមពលត្រូវបានប្រើប្រាស់។

របាយការណ៍នេះបានសន្និដ្ឋានថា
ដំណើរការធ្វើផែនការវិស័យថាមពល នៅក្នុងមហាអនុតំបន់មេគង្គមិនបានពិចារណាលើ ផលប៉ះពាល់បរិស្ថាននិងសង្គមនៅក្នុងប្រទេស ឬឆ្លងប្រទេស លើការប៉ាន់ស្មានហេតុផលនៃតម្រូវការ ឬលើការវិភាគចំណាយ-ចំណេញពីជម្រើសផ្សេងៗនោះទេ។ របាយការណ៍បានផ្តល់អនុសាសន៍ជាវិធីយ៉ាងច្រើនដើម្បីកែលម្អដំណើរការធ្វើផែនការថាមពលអគ្គិសនី ដូចជា ការធ្វើសមាហរណកម្មកង្វល់ផ្នែកបរិស្ថាន និងសង្គម ក៏ដូចជាចំណាយ និងការកែលម្អគុណភាពនៃការពិគ្រោះយោបល់ជាសាធារណៈជាដើម។

អនុសាសន៍នៃរបាយការណ៍ទាំងពីរនេះ ព្រមទាំងការសិក្សាថ្មីៗដែលបានបញ្ចប់នៅក្នុងខែមិថុនា ឆ្នាំ២០១៥ អំពីថាមពលកកើតឡើងវិញ និងប្រសិទ្ធផលថាមពលនៅតំបន់នេះ (គម្រោង 43301-012) ផ្តល់ព័ត៌មានយ៉ាងសំខាន់ដែលអាច - និងគប្បីត្រូវ - ណែនាំដល់ប្រតិបត្តិការ និងគណៈគ្រប់គ្រងរបស់ធនាគារពិភពលោក និងធនាគារអភិវឌ្ឍន៍អាស៊ីសម្រាប់ការវិនិយោគហេដ្ឋារចនាសម្ព័ន្ធថាមពល។

5 ទោះបីជា កម្មវិធីមុខរបរសម្រាប់ប្រជាជនដែលរងផលប៉ះពាល់មានបញ្ចូលគម្រោងចិញ្ចឹមត្រី និងដាំស្រូវតាមប្រព័ន្ធស្រោចស្រពក៏ដោយ ក៏ការតាមដានរយៈ ពេលវែងជាប្រព័ន្ធទៅលើបណ្តាសហគមន៍នៅក្នុងប្រទេសឡាវដែលរងផលប៉ះពាល់ដោយសារគម្រោងពង្រីក និងទំនប់ Theun-Hinboun ទំនប់ណាំធឿន២ និងទំនប់វារីអគ្គិសនីមុនៗ ដែលគាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ី ដូចជាគម្រោង ប្តូរទិស Nam Leak និង Nam Song បង្ហាញថា ការរៀបចំកម្មវិធីកាត់បន្ថយផលប៉ះពាល់នេះ ខកខានមិនបានស្តារឡើងវិញនូវប្រាក់ចំណូលលក្ខណៈគ្រួសារឲ្យមានសុវត្ថិភាពសេដ្ឋកិច្ចដូចមុនពេលមានដំណើរការសាងសង់របស់គម្រោងឡើយ។ ទាំងគម្រោងរបរចិញ្ចឹមត្រី ទាំងគម្រោងធ្វើស្រែមានប្រព័ន្ធស្រោចស្រព ទាមទារឱ្យមានដើមទុនចំណាយច្រើន ដែលជាញឹកញាប់មិនអាចទ្រទ្រង់បានដោយគ្រួសារប្រជាជន, ហើយទីបំផុតអាចធ្វើឱ្យពួកគាត់ជាប់បំណុលវ័ណ្ឌក ដោយសារពួកគាត់ព្យាយាមដោះស្រាយបន្ទុកបន្ថែម (ថៃទាំរក្សាស្រះត្រី ដូចជាចំណាយលើ ចំណី កូនត្រី និងគ្រឿងសំណង់ និងចំណាយលើជីដាក់ស្រែ ម៉ាស៊ីនបូមទឹកបញ្ចូលស្រែ និងត្រូវមានទឹកគ្រប់គ្រាន់)។

6 អាចរកមើលព័ត៌មានបន្ថែមតាមអាសយដ្ឋាននេះ http://www.adb.org/documents/assessment-greatermekong-subregion-energy-sector-development

7 គម្រោងលេខ ADB TA 7764, របាយការណ៍ស្តីពីផលប៉ះពាល់ៈ ធានានិរន្តរភាពនៃការអភិវឌ្ឍថាមពលនៅក្នុងតំបន់មហាអនុតំបន់មេគង្គ, ខែធ្នូ ឆ្នាំ២០១៣ [មិនទាន់ដាក់ឲ្យមើលតាមអន្តរបណ្តាញ (អ៊ីនធើណិត)។]



## ការផ្តល់អនុសាសន៍សម្រាប់ការសម្រេចចិត្តក្នុងការវិនិយោគថាមពលនៅមហាអនុតំបន់ទន្លេមេគង្គ

ជាសង្ខេប យើងសូមផ្តល់អនុសាសន៍ជូនធនាគារពិភពលោក និងធនាគារអភិវឌ្ឍន៍អាស៊ីឲ្យផ្អាករាល់គម្រោងវិនិយោគលើវិស័យថាមពលនៅមហាអនុតំបន់ទន្លេមេគង្គទាំងអស់ ដែលបានគ្រោងឡើង រហូតដល់ពេលមានការបញ្ជាក់ច្បាស់លាស់ថាៈ

- ការព្យាករថាមពលថ្នាក់ជាតិ ក៏ដូចជាថ្នាក់តំបន់ ត្រូវមានការត្រួតពិនិត្យយ៉ាងត្រឹមត្រូវ ដើម្បីធានាបាននូវតម្រូវការសម្រាប់គម្រោងដែលបានស្នើឡើង,
- ត្រូវចាត់ជាអាទិភាព និងធ្វើការពិចារណាពេញលេញ នូវជម្រើសទាំងអស់ដើម្បីបំពេញតម្រូវការថាមពលដូចបានគ្រោងទុក,
- វាយតម្លៃលើរបាយការណ៍ស្តីពីការវាយតម្លៃយ៉ាងល្អិតល្អន់អំពីជម្រើសនានាសម្រាប់សំណើគម្រោង ក្នុងលក្ខណៈមានតម្លាភាព និងផ្សព្វផ្សាយជាសាធារណៈ,
- អនុវត្ត ផ្សព្វផ្សាយជាសាធារណៈ និងចែករំលែកជាមួយប្រជាជនដែលរងផលប៉ះពាល់ នូវការវាយតម្លៃផលប៉ះពាល់ឆ្លងដែនចំពោះមុខយ៉ាងហ្មត់ចត់,
- ការចំណាយពេញលេញលើសង្គមនិងបរិស្ថានសម្រាប់វដ្តគម្រោងត្រូវបានបញ្ចូលទៅក្នុងការវិភាគចំណាយ-ចំណេញរបស់គម្រោងដែលផ្សព្វផ្សាយជាសាធារណៈ,
- ការដ្ឋានគម្រោងដែលបានស្នើឡើង មិនបំផ្លាញ ឬធ្វើឲ្យលេចលង់ទីកន្លែងសំខាន់ៗដែលមានតម្លៃសង្គម អេកូឡូស៊ី វប្បធម៌ និង/ឬសេដ្ឋកិច្ច,
- ប្រជាជនដែលរងផលប៉ះពាល់ត្រូវទទួលបាននូវការពិគ្រោះយោបល់ជាផ្លែផ្កា និងផ្តល់ការយល់ព្រមដោយគ្មានការបង្ខិតបង្ខំ និងទទួលបានព័ត៌មានជាមុន សម្រាប់គម្រោងនានា, និង
- ប្រជាជនដែលទទួលរងផលប៉ះពាល់មានលទ្ធភាពទទួលបានដំណោះស្រាយ និងប្រើប្រាស់យន្តការដោះស្រាយបណ្តឹងប្រកបដោយប្រសិទ្ធភាព ដែលត្រូវបានកំណត់តាំងពីពេលចាប់ផ្តើម និងដំណើរការមួយវដ្តគម្រោង,

លើសពីនេះទៅទៀត ចំពោះបណ្តាគម្រោងដែលទទួលបានការអនុម័ត ហើយការរំលោភច្រំដែលៗលើគោលការណ៍សុវត្ថិភាព ត្រូវបានកត់សម្គាល់ដោយប្រជាជនរងផលប៉ះពាល់ និង/ឬក្រុមសង្គមស៊ីវិល យើងផ្តល់អនុសាសន៍ថា គប្បីត្រូវផ្អាកមូលនិធិដែលមិនទាន់ដកប្រើប្រាស់ទុកសិន ខណៈពេលដែលក្តីព្រួយបារម្ភទាំងនេះត្រូវបានស៊ើបអង្កេត រហូតដល់មានវិធាននៃការកាត់បន្ថយផលប៉ះពាល់ល្អិតល្អន់សម្រាប់ដោះស្រាយពេញលេញនូវស្ថានភាពនោះ។

---

INTERNATIONAL RIVERS
people • water • life

**អង្គការទន្លេអន្តរជាតិ** ជាអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ ដែលធ្វើការនៅជុំវិញពិភពលោកដើម្បីការពារទន្លេនិងការពារសិទ្ធិរបស់បណ្តាសហគមន៍ដែលរស់នៅដោយពឹងផ្អែកលើទន្លេ។ អង្គការទន្លេអន្តរជាតិធ្វើការដើម្បីបញ្ឈប់គម្រោងទំនប់ដែលមានការបំផ្លិចបំផ្លាញ និងជំរុញដំណោះស្រាយបញ្ហាទឹក និងថាមពលសម្រាប់ពិភពលោកមានយុត្តិធម៌ និងនិរន្តរភាព។

Mekong Watch

**អង្គការឃ្លាំមើលទន្លេមេគង្គ** ជាអង្គការបរិស្ថានមិនមែនរដ្ឋាភិបាលមួយដែលមានមូលដ្ឋាននៅទីក្រុងតូក្យូ។ អង្គការនេះឃ្លាំមើលគម្រោងអភិវឌ្ឍន៍ធំៗនៅតាមអាងទន្លេមេគង្គ ជាពិសេសបណ្តាគម្រោងអភិវឌ្ឍន៍ដែលពាក់ព័ន្ធនឹងមូលនិធិសាធារណៈនិងឯកជនជប៉ុន។ អង្គការឃ្លាំមើលទន្លេមេគង្គធ្វើការយ៉ាងជិតស្និទ្ធជាមួយបណ្តាសហគមន៍មូលដ្ឋាន និងអង្គការសង្គមស៊ីវិលនានា ដើម្បីបញ្ចៀស និងកាត់បន្ថយផលប៉ះពាល់បរិស្ថាន សង្គម និងសិទ្ធិមនុស្ស ដោយសារគម្រោងអភិវឌ្ឍទ្រង់ទ្រាយធំ។

Printed on recycled paper